ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣២៩ ប្រក. កសក

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីសហគមន៍នេសាទចំនួន១០ នៅខេត្តក្រចេះ តាកែវ បន្ទាយមានជ័យ និងខេត្តកោះកុង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាននិងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : ០២៣ / ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវសហគមន៍នេសាទចំនួន១០រួមមាន៖ ខេត្តក្រចេះចំនួន០២សហគមន៍ ខេត្តតាកែវចំនួន០៣សហគមន៍ ខេត្តបន្ទាយមានជ័យចំនួន០៣សហគមន៍ និងខេត្តកោះកុងចំនួន០២សហគមន៍ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកា ជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ដូចមានចែងក្នុងប្រការ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៤.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឪវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ឹក រ៉ាប៊ុន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ:** ភ្ជាប់ប្រកាសលេខ......៣២៩ ប្រក.កសក......ចុះថ្ងៃទី ១៤.........ខែ កក្កដា.........ឆ្នាំ២០១៤

## សហគមន៍នេសាទក្នុងខេត្តក្រចេះ តាកែវ បន្ទាយមានជ័យ និងខេត្តកោះកុង

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក (នាក់) | ចំនួនសមាជិកគណៈកម្មការ (នាក់) | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ | ស្រុក | Projection : UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | (X,Y) | (X,Y) |
| **១-ខេត្តក្រចេះ** | | | | | | | | | |
| ១ | កំពង់ក្បឿង | ១៦៣ | ០៩ | ៣.៧៤២ | កំពង់ក្បឿង | បឹងចារ | សំបូរ | A. (608435, 1451908)<br>B. (609805, 1454457)<br>C. (608462, 1456982)<br>D. (604770, 1458956) | E. (604477, 1459890)<br>F. (608169, 1461347)<br>G. (613041, 1457663)<br>H. (608796, 1450581) |
| ២ | អូរក្រសាំង | ៨៧ | ០៩ | ៩៣៨,៥ | អូរក្រសាំង | បឹងចារ | សំបូរ | A. (608867, 1449952)<br>B. (607760, 1431252)<br>C. (606990, 1429593)<br>D. (606142, 1429915) | E. (606766, 1431085)<br>F. (606909, 1433862)<br>G. (607540, 1437085)<br>H. (608191, 1435780) |
| **២-ខេត្តតាកែវ** | | | | | | | | | |
| ១ | កំពង់ក្រសាំង | ១៦៦ | ១១ | ៦.៨៤០ | កំពង់ក្រសាំង ក្តុលជ្រុំ បូរីជលសារ ថ្មបីដុំ និងសង្គមមានជ័យ | កំពង់ក្រសាំង | បូរីជលសារ | A. (506528, 1195014)<br>B. (501018, 1195006)<br>C. (502003, 1189895)<br>D. (507999, 1186008) | E. (511156, 1184839)<br>F. (508635, 1190897)<br>G. (507109, 1193413)<br>H. (506563, 1193686) |
| ២ | បូរីជលសារ | ៣៣៣ | ០៩ | ៦.៧០០ | អន្លង់ទៀន អង្គក្រូច ក្អែកយំ ព្រៃកខ្សាច់ កំពង់អំពិល ដើមគរ និងស្វាយដូច | បូរីជលសារ | បូរីជលសារ | A. (500521, 1201981)<br>B. (492017, 1201976)<br>C. (491985, 1198317)<br>D. (494529, 1197977) | E. (496324, 1195835)<br>F. (499991, 1195993)<br>G. (501019, 1195006)<br>H. (505766, 1197854) |
| ៣ | គោកធ្លក | ៨៦ | ០៧ | ៦.៤៩០ | ទួលពុទ្រា ព្រៃកជា ព្រៃកតាផ និងបាក់ដៃ | គោកធ្លក | អង្គរបុរី | A. (503908, 1213029)<br>B. (498987, 1212987)<br>C. (498954, 1203403)<br>D. (505766, 1197854) | E. (504275, 1201015)<br>F. (503898, 1203796)<br>G. (504456, 1204291)<br>H. (503935, 1205423) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣-ខេត្តបន្ទាយមានជ័យ | | | | | | | | | |
| ១ | សំបូរ | ៣៣៤ | ១១ | ៧០៥ | សំបូរ | សំបូរ | មង្គលបុរី | A. (304350, 1486455)<br>B. (306145, 1483938) | C. (304550, 1487380)<br>D. (304000, 1482400) |
| ២ | ស្រណាល | ៣៩២ | ០៩ | ១.៥៩៧ | ស្រណាល | សំបូរ | មង្គលបុរី | A. (302076, 1489084)<br>B. (300725, 1482150)<br>C. (304000, 1482400) | D. (304550, 1487380)<br>E. (302850, 1488220) |
| ៣ | ដូនឡឹក | ៤២៥ | ១១ | ១.០៤៥ | ដូនឡឹក ក្បាលក្របី ស្រះឈូក និង ស្រែព្រៃ | សំបូរ | មង្គលបុរី | A. (304350, 1486455)<br>B. (306145, 1483938)<br>C. (304000, 1482400) | D. (307056, 1480578)<br>E. (307500, 1485850) |
| ៤-ខេត្តកោះកុង | | | | | | | | | |
| ១ | សម្រស់កោះស្ដេច | ៤០១ | ០៩ | ១៦.១៥៨ | កោះស្ដេច | កោះស្ដេច | គីរីសាគរ | A. (293535, 1218779)<br>B. (285202, 1218965)<br>C. (283932, 1215905)<br>D. (288311, 1202919) | E. (298577, 1196726)<br>F. (300259, 1201234)<br>G. (295772, 1204923)<br>H. (293768, 1212932) |
| ២ | តំបន់ឆ្នេរសមុទ្រឃុំ ពាមក្រសោប | ២១០ | ០៧ | ២.២៧២ | ភូមិ១<br>ភូមិ២ | ពាមក្រសោប | បណ្ដូលសីមា | A. (281280, 1269929)<br>B. (279161, 1268570)<br>C. (275502, 1273642)<br>D. (277369, 1275686) | E. (279874, 1268855)<br>F. (279781, 1268977)<br>G. (280331, 1269390)<br>H. (280421, 1269273) |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៤
**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

បណ្ឌិត ណៅ_ធួក